# យុទ្ធសាស្ត្រទី ១ : ការបង្កើតការងារ

ទិសដៅចំបង៧របស់ក្រសួង នៅក្នុងយុទ្ធសាស្ត្រនៃការបង្កើតការងារ គឺការអភិវឌ្ឍមុខរបរក្នុងប្រទេស និងការអភិវឌ្ឍការងារនៅក្រៅប្រទេស ។

## ១. ការអភិវឌ្ឍមុខរបរក្នុងប្រទេស

ក្នុងទិសដៅនៃការអភិវឌ្ឍមុខរបរក្នុងប្រទេស គឺត្រូវធ្វើការសិក្សា និង រៀបចំគោលនយោបាយជាតិ ស្តីពីការគ្រប់គ្រងមុខរបរ និងហត្ថពលកម្ម កែលំអប្រព័ន្ធគ្រប់គ្រងការប្រើប្រាស់ពលកម្មក្នុងប្រទេស និងរួមចំណែកបង្កើតការងារ ដើម្បីបង្កើនប្រាក់ចំណូល ។

### 1.1- សិក្សា និង រៀបចំគោលនយោបាយជាតិស្តីពីការគ្រប់គ្រងមុខរបរ និងហត្ថពលកម្ម

- ប្រមូលទិន្នន័យសេដ្ឋកិច្ច និងសង្គមកិច្ចដែលជាប់ទាក់ទងនឹងមុខរបរ ដើម្បីទទួលបាននូវព័ត៌មានស្តីពីតម្រូវការពលកម្ម និងព័ត៌មានស្តីពីការផ្គត់ផ្គង់ពលកម្ម
- ធ្វើចំណាត់ថ្នាក់មុខរបរ ដើម្បីទទួលបាននូវបញ្ជីឈ្មោះនៃមុខរបរ ។

### 1.2- កែលំអប្រព័ន្ធគ្រប់គ្រងការប្រើប្រាស់ពលកម្ម ក្នុងប្រទេស

- លើកកំពស់ការងារគ្រប់គ្រងកម្មករនិយោជិតខ្មែរនៅតាមសហគ្រាស គ្រឹះស្ថានឯកជន ដើម្បីទទួលបាននូវទិន្នន័យ

ស្ដីពីសហគ្រាស និងកម្មករនិយោជិតខ្មែរ តាមប្រព័ន្ធ អេឡិចត្រូនិក
និងការរកឃើញនិន្នាការនៃតម្រូវការ ទីផ្សារការងារក្នុងស្រុក

- លើកកំពស់ការងារគ្រប់គ្រងហត្ថពលកម្មបរទេសនៅតាមសហគ្រាស គ្រឹះស្ថានឯកជន ដើម្បីទទួលបានទិន្នន័យស្ដីពីសហគ្រាស និងកម្មករនិយោជិតបរទេសតាមប្រព័ន្ធអេឡិចត្រូនិក និងមើលឃើញតម្រូវការកំលាំងពលកម្មក្នុងស្រុកដែលមិនទាន់មានសម្រាប់បំពេញ ឱ្យសេចក្ដីត្រូវការនៃកិច្ចអភិវឌ្ឍ
- ប្រមូល និងបង់អាករប័ណ្ណ និងសៀវភៅការងារតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើឱ្យកម្មករនិយោជិតទទួលបានប័ណ្ណ និងសៀវភៅការងារខ្មែរ និងធ្វើការប្រមូលអាករ តាមផែនការកំណត់ ។

## ១៣. រួមចំណែកបង្កើតការងារដើម្បីបង្កើនប្រាក់ចំណូល

- សិក្សាស្រាវជ្រាវសក្ដានុពលមុខរបរបន្ថែមឬតាមរដូវស្របទៅតាមតម្រូវការទីផ្សារចំពោះមុខ
- ពិគ្រោះយោបល់ និងតម្រង់ទិសវិជ្ជាជីវៈ ដោយផ្ដល់សេវាអប់រំណែនាំ និងបណ្ដុះបណ្ដាលរយៈពេលខ្លីៗ ដើម្បីទទួលបាននូវចំណេះដឹង និងចំណេះធ្វើមុខរបរខ្នាតតូច

- គាំទ្រខាងបច្ចេកទេសដើម្បីធានានិរន្តរភាពមុខរបរ ដើម្បីពលរដ្ឋមានការងារធ្វើ និងការងារបន្ថែម និងធ្វើឱ្យប្រាក់ចំណូលកើនឡើង ឈានដល់សម្រេចគោលដៅលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជន ។

## ២. ការអភិវឌ្ឍការងារនៅបរទេស

ក្នុងទិសដៅនៃការអភិវឌ្ឍការងារនៅបរទេស គឺធ្វើការកែលំអការគ្រប់គ្រងការផ្តល់សេវាមុខរបរនៅក្រៅប្រទេសតាមរយៈក្រុម-ហ៊ុនឯកជន ការបង្កើតប្រព័ន្ធ សាធារណៈនៃសេវាមុខរបរក្រៅប្រទេស និងការការពារពលករទេសន្តរប្រវេសន៍ ។

### 2.1- កែលំអការគ្រប់គ្រងការផ្តល់សេវាមុខរបរនៅក្រៅប្រទេសតាមរយៈក្រុមហ៊ុនឯកជន

- ពិនិត្យ និងជ្រើសរើសយកតែក្រុមហ៊ុនណា ដែលមានសមត្ថភាពពេញលេញ ឱ្យធ្វើការងារបញ្ជូនពលករខ្មែរទៅធ្វើការនៅក្រៅប្រទេសសំដៅធានាឱ្យបានថា ក្រុមហ៊ុនទាំងឡាយណាដែលនៅ បន្តធ្វើការងារបញ្ជូនពលករទៅបរទេសជាក្រុមហ៊ុនមានសមត្ថភាព គ្រប់គ្រាន់ក្នុងការការពារសិទ្ធិ និងផលប្រយោជន៍របស់ពលករ និងទទួលខុសត្រូវខ្ពស់ចំពោះមុខរាជរដ្ឋាភិបាល ក៏ដូចជាក្រសួង
- តាមឃ្លាំមើលជាប្រចាំ និងធ្វើការណែនាំតម្រង់ទិសក្រុមហ៊ុនឯកជនដែលធ្វើការបញ្ជូនពលករខ្មែរ ទៅធ្វើការនៅ

ក្រៅប្រទេស សំដៅឱ្យមានការលើកកំពស់ប្រសិទ្ធភាព ការងារជ្រើសរើស ការងារបញ្ជូន និងការងារគ្រប់គ្រង ពលកររបស់ក្រុមហ៊ុនទាំងនោះ

- ជម្រុញឱ្យក្រុមហ៊ុនធ្វើការនាំពលករទៅក្រៅប្រទេសអនុវត្តឱ្យបានត្រឹមត្រូវតាមគោលការណ៍នានា ទាក់ទងដល់ការបញ្ជូនពលករទៅក្រៅប្រទេស សំដៅធ្វើឱ្យការអនុវត្ត បានត្រឹមត្រូវទៅតាមអនុក្រឹត្យលេខ៥៧ របស់រាជរដ្ឋាភិបាល តាមច្បាប់ជាតិ និងអនុសញ្ញាអន្តរជាតិ
- បង្កើតឱ្យមានបណ្តាញផ្តល់សេវាការពារ ពលករខ្មែរដែលធ្វើការនៅក្រៅប្រទេសសំដៅធ្វើឱ្យមានបណ្តាញមួយដែលមានប្រសិទ្ធភាពក្នុងការគ្រប់គ្រងព័ត៌មាន និងទិន្នន័យដែលស្តីពីពលកម្មខ្មែរនៅបរទេស ។

## 2.2- ***បង្កើតប្រព័ន្ធសាធារណៈនៃសេវាមុខរបរក្រៅប្រទេស***

- ទំនាក់ទំនងជាមួយប្រទេស ដែលទទួលពលករដើម្បីក្តាប់ព័ត៌មាន និងតម្រូវការទីផ្សារការងារ ហើយដោះស្រាយឱ្យបានទាន់ពេលវេលា
- សម្របសម្រួល ឱ្យបានជិតស្និទ្ធជាមួយស្ថាប័នពាក់ព័ន្ធក្នុងប្រទេស ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការជ្រើសរើសបណ្តុះបណ្តាលបញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបរទេស

- កសាងបទដ្ឋានលក្ខណៈវិនិច្ឆ័យ និងនីតិវិធីឱ្យបានគ្រប់ជ្រុងជ្រោយក្នុងការជ្រើសរើស និងអប់រំបណ្តុះបណ្តាលដើម្បីបំពេញសំណូមពរ និងលក្ខខណ្ឌរបស់ប្រទេសជាដៃគូប្រកបដោយតម្លាភាព
- រៀបចំ និងចាត់ចែងបែបបទបញ្ជូន និងគ្រប់គ្រងពលករដែលទៅធ្វើការនៅក្រៅប្រទេសរហូត ដល់ពួកគេបានត្រឡប់មកមាតុប្រទេសវិញ ។

## ២.៣. ការពារពលករទេសន្តរប្រវេសន៍ គឺសហការជាមួយក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងកិច្ចការនារី អាជ្ញាធរមូលដ្ឋាននិងអង្គការមិនមែនរដ្ឋាភិបាល

- លើកកំពស់ការយល់ដឹង អំពីផលវិបាកនានានៃទេសន្តរប្រវេសន៍ ជាពិសេសទេសន្តរប្រវេសន៍មិនត្រឹមត្រូវតាមច្បាប់ដើម្បីជៀសវាងការរំលោភសិទ្ធិ និងកេងប្រវ័ញ្ចផលប្រយោជន៍របស់ពួកគេ
- លើកកំពស់ការយល់ដឹងអំពីច្បាប់ និងគោលការណ៍នានាដែលពាក់ព័ន្ធ ដើម្បីរួមចំណែកក្នុងការការពារខាងផ្លូវច្បាប់ចំពោះពលករកម្ពុជានិរប្រវេសន៍
- លើកកំពស់ការយល់ដឹងអំពី HIV/AIDS រួមចំណែកក្នុងការការពារពលករកម្ពុជានិរប្រវេសន៍

- លើកកំពស់ការយល់ដឹង អំពីសិទ្ធិជាមូលដ្ឋាននៅកន្លែងធ្វើការ ដើម្បីរួមចំណែកក្នុងការការពារសិទ្ធិ និងផលប្រយោជន៍របស់ពលករកម្ពុជានិរប្រវេសន៍ ។